**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១៤៦,៩១ ហិកតា នៅស្រុកកោះញែក ខេត្តមណ្ឌលគិរី ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២៣៣ លសមគរ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគិរី
- លិខិតលេខ ២៤៦ លសមគរ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគិរី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ១៤៦,៩១ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ១៤១,០១ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥,៩០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិសិរីមង្គល ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគិរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិសិរីមង្គល ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសរុប ១៨២ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១៨០ ក្បាលដី ជូនប្រជាពលរដ្ឋ ៦៤ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០២ ក្បាលដី (ដីអណ្តូងទឹក) ។



www.pheakdeylaw.com

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ៥៧៣ អនក្រ.បក. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣

គំនូសបង្ហាញទីតាំងដីដែលកាត់ពីតំបន់ព្រៃ តាមរូបថតឆ្នាំ ២០០២

សរុបចំនួន ១៤៦,៥១ហិកតា ភូមិសេរីមង្គល ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី




| | | | | | |
|---|---|---|---|---|---|
| 1 | 717072 | 1442589 | 16 | 719223 | 1441931 |
| 2 | 717148 | 1442544 | 17 | 718969 | 1442058 |
| 3 | 717487 | 1442234 | 18 | 718974 | 1442079 |
| 4 | 718336 | 1441472 | 19 | 718275 | 1442514 |
| 5 | 718506 | 1441382 | 20 | 718109 | 1442357 |
| 6 | 718634 | 1441362 | 21 | 717986 | 1442455 |
| 7 | 718794 | 1441668 | 22 | 718005 | 1442495 |
| 8 | 718915 | 1441648 | 23 | 717986 | 1442516 |
| 9 | 718953 | 1441648 | 24 | 717895 | 1442640 |
| 10 | 719262 | 1441513 | 25 | 717288 | 1443003 |
| 11 | 719293 | 1441561 | 26 | 717212 | 1442965 |
| 12 | 719321 | 1441546 | 27 | 717176 | 1442870 |
| 13 | 719373 | 1441731 | 28 | 717172 | 1442806 |
| 14 | 719370 | 1441792 | 29 | 717117 | 1442741 |
| 15 | 719187 | 1441831 | | | |

**សញ្ញាសម្គាល់**

ឧបករណ៍វាស់វែង GPS Map Garmin 62s

0 500 1,000 Meters

- ចំនុចបង្គោលព្រំដី

ដីកាត់ពីតំបន់ព្រៃឆ្នាំ ២០០២ ទំហំ១៤៦.៥១ហិកតា

COORDINATE SYSTEM
Projection : UTM
Zone : 48 N
Horizontal Datum : WGS 1984
GPS Model : Garmin 62 CS

បានឃើញ និង ឯកភាព

មណ្ឌលគិរី, ថ្ងៃទី ខែ ឆ្នាំ២០១៣

អភិបាលខេត្តមណ្ឌលគិរី

អ្នកវាស់វែង

មណ្ឌលគិរី ថ្ងៃទី ខែ ឆ្នាំ ២០១៣

## ផែនទីបង្ហាញក្បាលដីជាន់លើ គម្របព្រៃឆ្នាំ២០០២
## ស្ថិតនៅភូមិសិរីមង្គល ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី

